ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រម(មុនអន្តសេចក្តី)

លេខ: ១០ "ឃ១"

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៣២៦៨

ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ: ១៤០៨

ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១

-សំណុំរឿងជំនុំជំរះលេខ: ២៩៩៧

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ៣០ ព្រឹក នាសាលសវនាការទី០៦ ដោយមានសមាសភាពដូចខាងក្រោម ៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៦៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **សុផល** ហៅ **ឆា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧០ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នស្នាក់នៅលើ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សួន "ស្លាប់" ម្តាយឈ្មោះ [redacted] ប៉ិត "ស្លាប់" ប្រពន្ធឈ្មោះ [redacted] ចាន់ផន "រស់" មានកូន០៥នាក់ ជានីតិជន ទោសពីមុនគ្មាន។

-ឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលេខ ១៣៧២ "ឃ១" ដ.ច.ន ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ។

ជាប់ចោទពីបទ **ឆបោក** និងបទ **ក្លែងបន្លំ (ស្លាមមេដៃ)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ មាត្រា៦២៦ មាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ។

-មានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ឆា** មានការិយាល័យនៅផ្លូវរបេតុង ភូមិរោងចក្រ សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីវលីង** ([redacted] HSIU LING) ភេទស្រី កើតឆ្នាំ១៩៦៥ ជនជាតិចិនតៃវ៉ាន់ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ១៧ ផ្លូវលេខ០៨ ភូមិម៉ល សង្កាត់ផង្កា



Scanned with CamScanner

ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ចាង ស៊ីវលីង មានការិយាល័យនៅផ្ទះលេខ១៤៣ ផ្លូវលេខ២០២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីអំឡុងខែមិថុនា ឆ្នាំ២០១៨ ឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានផានារៀបចំទិញដីពីប្រជាពលរដ្ឋជាច្រើនគ្រួសារ មានទំហំសរុប ១២៣,៧៩៧.៩៩៩ម² (ដប់ពីរម៉ឺនបីពាន់ប្រាំពីររយកៅសិបប្រាំពីរក្បៀសប្រាំបួនរយកៅសិបប្រាំបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិពង្រ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឱ្យទៅឈ្មោះ [redacted] ស៊ីវលីង ([redacted] HSIU LING) ជនជាតិចិនតៃវ៉ាន់ និងជាប្រធានក្រុមហ៊ុនហុងឡុង ស៊ូ ឯ.ក (HONG LONG SHOE CO.,LTD) ដោយឈ្មោះ [redacted] រី ទទួលបន្ទុកជាអ្នកបកប្រែផង និងជាអ្នកចុះកិច្ចសន្យាទិញលក់ដីផងជាមួយឈ្មោះ [redacted] ស៊ីវលីង ([redacted] HSIU LING) រីឯឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន ជាអ្នកផានា ហើយរាល់ពេលទទួលប្រាក់គឺអ្នកទាំងបីនាក់បានទៅបើកយកប្រាក់នៅធនាគារទាំងអស់គ្នា ជាច្រើនលើកច្រើនសារសរុបចំនួន ៦៦០,000 (ហុកសិបប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលប្រាក់ទាំងអស់នេះ ត្រូវបានឈ្មោះ [redacted] រី ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន យកទៅកក់ឱ្យប្រជាពលរដ្ឋបានមួយចំនួន និងអ្នកខ្លះទៀតទទួលបានគ្រប់ចំនួន និងនៅសល់ប្រជាពលរដ្ឋមួយចំនួនទៀតទទួលបានប្រាក់កក់តែប៉ុណ្ណោះ។ លុះក្រោយមកឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានរៀបចំធ្វើឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ដោយដាក់ឈ្មោះរបស់ប្រជាពលរដ្ឋដែលបានកក់ប្រាក់នោះ គឺមានឈ្មោះ [redacted] យន ដែលចម្លើយរបស់ឈ្មោះ [redacted] យន បានអះអាងថា នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ៨២០/១៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ដែលមានចុះហត្ថលេខាមេភូមិពង្រ ឈ្មោះ [redacted] សុង បានប្រថាប់ត្រាដោយលោកមេឃុំស្រង់ ឈ្មោះ [redacted] ប៉េង គឺមិនមែនស្នាមមេដៃរបស់គាត់នោះទេ ឈ្មោះ កែវ ពេះ និងប្រពន្ធឈ្មោះ [redacted] រីណា ដែលចម្លើយអ្នកទាំងពីរបានឆ្លើយថា នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ ៨១៧/១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨ មិនមែនស្នាមមេដៃរបស់ពួកគាត់ទេ។ ចំណែកចម្លើយរបស់ឈ្មោះ [redacted] ហ៊ាន, ឈ្មោះ [redacted] សំណាង, ឈ្មោះ [redacted] ចាន់ធឿន, ឈ្មោះ [redacted] ប៉ក់ និងឈ្មោះ [redacted] ទូច សុទ្ធតែបានឆ្លើយដូចគ្នាថា នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលមានស្នាមមេដៃពួកគាត់នោះគឺពួកគាត់បានអះអាងថា ពុំដែលបានផ្ដិតមេដៃទេ គឺពួកគាត់ធ្លាប់បានផ្ដិតមេដៃលើលិខិតកក់ប្រាក់តែប៉ុណ្ណោះ ហើយឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុខន និងឈ្មោះ [redacted] សុផល បានយកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនេះ ទៅចុះហត្ថលេខាលោកមេភូមិពង្រ ឈ្មោះ [redacted] សុង និងលោកមេឃុំស្រង់ ឈ្មោះ [redacted] ប៉េង ដោយលោកមេភូមិ និងលោកមេឃុំ បានអះអាងថា នៅពេលចុះហត្ថលេខា គឺមានស្នាមមេដៃរបស់ប្រជាពលរដ្ឋរួចហើយ ដោយពុំបានផ្ដិតមេដៃចំពោះមុខខ្លួននោះទេ ហើយខ្លួនក៏ពុំបានដឹងថាស្នាមមេដៃទាំងអស់ជាស្នាមមេដៃរបស់នរណាឡើយ ហើយឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានយកលិខិតផ្ទេរសិទ្ធិទាំងនេះទៅយកប្រាក់ពីក្រុមហ៊ុន ហុងឡុង ស៊ូ ឯ.ក (HONG LONG SHOE CO., LTD បន្ថែមទៀត ។ តែក្រុមហ៊ុនបានដឹងគំនិតទុច្ចរិតរបស់អ្នកទាំងបីខាងលើនេះ ក្រុមហ៊ុនពុំបានប្រគល់ប្រាក់ឱ្យទៀតទេ ព្រោះឈ្មោះ [redacted] រី ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សុខន បានយកប្រាក់ពីក្រុមហ៊ុនអស់ចំនួន ៦៦០,000 USD (ហុកសិបប្រាំមួយម៉ឺន) ដុល្លារអាមេរិក ទៅហើយ តែប្រមូលទិញដីបានមួយចំនួនតូចតែប៉ុណ្ណោះ ប្រហែល ០៥ ហិចតា ឯប្រាក់បានយកពីក្រុមហ៊ុនជិតគ្រប់ចំនួនហើយ។ ចំពោះដីដែលឈ្មោះ [redacted] រី, ឈ្មោះ [redacted] សុផល និងឈ្មោះ



Scanned with CamScanner

[redacted] សុខន បានរៀបចំទិញ នោះគឺពុំជាប់គ្នាទេ គឺមានចន្លោះប្រហោងជាច្រើនកន្លែង ជាហេតុធ្វើឱ្យក្រុមហ៊ុនពុំអាចទទួលយកបានក្នុងការធ្វើរោងក្រ ឡើយ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋបានទទួលប្រាក់កក់នោះអះអាងថា ពួកខ្លួននៅតែលក់ដដែល តែមូលហេតុមកពី ឈ្មោះ [redacted] រី ឈ្មោះ [redacted] ពៅ សុខន មិនព្រមយកប្រាក់ដែលទទួលបានពីក្រុមហ៊ុនមកឱ្យពួកខ្លួនបង្គ្រប់។

**បានឃើញ** ពាក្យសុំដោះលែងកូនក្ដីឱ្យនៅក្រៅឃុំ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ធា** ។

**-បានឃើញ** ពាក្យបណ្ដឹងចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង ([redacted] HSIU LING) បានបណ្ដឹងចូលមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ **១២១៩ អ.យ.ក** ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ **របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ **២៧០៧ អ.យ.ក** ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ **របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។**

**-បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ៣៧៨៧ "ខ" ជ.ជ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា បានឆ្លើយថា៖ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ មេធាវីការពារ សិទ្ធិឱ្យរូបខ្លួនបានដាក់ពាក្យសុំឱ្យនៅក្រៅឃុំដោយមូលហេតុថាខ្លួនមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ហើយត្រូវការមើលថែយ៉ាង ជិតដិតពីសំណាកគ្រូពេទ្យជាប្រចាំ តាំងពីថ្ងៃដែលខ្លួនចូលក្នុងមណ្ឌលអប់រំកែប្រែទី១ "ម១" មកខ្លួនមានការថប់ដង្ហើម ,វិលមុខ ស្រវាំងភ្នែក រោយក ,ដេកមិនលក់ នោមញឹក អស់កំលាំង, ជាតិស្ករក្នុងឈាមឡើងខ្ពស់ និងសម្ពាធឈាមឡើងខ្ពស់ ហើយត្រូវលេបថ្នាំជាប្រចាំនៅក្នុងមណ្ឌល ដោយសារស្ថានភាពជំងឺនេះចាំបាច់ត្រូវការព្យាបាលពីគ្រូពេទ្យជំនាញ។ ម្យ៉ាងវិញទៀត ខ្លួនមានកូនចំនួន០២នាក់ ដែលជាអនីតិជន នៅក្នុងបន្ទុកដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាអប់រំ ក្រៅពីរូបខ្លួនគឺមិន មានអ្នកណាមើលថែនោះទេ ហើយរូបខ្លួនក៏ត្រូវបង់ធនាគារ ដែលខ្លួនបានខ្ចីថែមទៀតផង។ ខ្លួនសូមសន្យាថា បើតុលាការ អនុញ្ញាតឱ្យរូបខ្លួនបាននៅក្រៅឃុំនោះ គឺរូបខ្លួនមិនគេចវេះទៅណាឡើយ ព្រោះអចលវត្ថុរបស់ខ្លួនត្រូវបានតុលាការចេញ ដីកាសម្រេចរក្សាការពារលេខ ២៥០ "ញ" ជ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ រួចរាល់ហើយ។

**<u>សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី</u>**

លោក [redacted] ជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង ភេទស្រី បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ, ឃើញថា ជនជាប់ចោទគ្មានចេតនាដោះស្រាយចរចាជាមួយកូនក្ដីរបស់ខ្លួននៅលើបញ្ហាដែលធ្លាប់បានប្រព្រឹត្តកន្លងមក។ ហើយ ជនជាប់ចោទបានបញ្ជាក់ថាខ្លួនមានជំងឺជាប្រចាំ និងមានកូនតូច ដែលនៅក្នុងបន្ទុក កំពុងមានជំងឺថែមទៀតផង ការលើកឡើងពីបញ្ហាជំងឺនេះ គឺគ្រាន់តែជាលេសមួយដើម្បីឱ្យខ្លួនបាននៅក្រៅឃុំតែប៉ុណ្ណោះ ប្រសិនបើតុលាការអនុញ្ញាតឱ្យជនជាប់ចោទ

នៅក្រៅឃុំនោះ ជនជាប់ចោទនិងប្រព្រឹត្តបទល្មើសថ្មី បន្ថែមទៀត ដែលបណ្តាលឱ្យមានភាពវឹកវរដល់សង្គម ។ ដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យតុលាការមេត្តារក្សាជនជាប់ចោទឱ្យនៅក្នុងពន្ធនាគារបន្តទៀតដោយក្តីអនុគ្រោះ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ស្នើសុំឱ្យតុលាការធ្វើការឃុំខ្លួនជនជាប់ចោទជាបន្តទៅទៀត ការប្តឹងសុំរបស់ជនជាប់ចោទនេះគឺពុំមានមូលហេតុគ្រប់គ្រាន់ ហើយប្រសិនបើឱ្យជនជាប់ចោទនៅក្រៅឃុំនោះ និងអាចមានភាពច្របូកច្របល់ដែលបង្ករឡើងដោយជនជាប់ចោទ ម្យ៉ាងវិញទៀតជនជាប់ចោទ មិនទាន់បានសងសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមិនមានការភ្ញាក់រលឹកពីទង្វើដែលខ្លួនបានប្រព្រឹត្តនោះឡើយ ។ ហេតុដូចនេះ តំណាងអយ្យការ ស្នើសុំដល់ឱ្យរក្សាការឃុំខ្លួនជនជាប់ចោទបន្តដើម្បីទុកជូនតុលាការចាត់ការតាមនីតិវិធី ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ផា បានធ្វើសេចក្តីសន្និដ្ឋានថា៖ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ មេធាវីការពារ ខ្លួនបានដាក់ពាក្យសុំឱ្យនៅកូនក្តីនៅក្រៅឃុំដោយសារតែកូនក្តីរបស់ខ្លួនមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ហើយត្រូវការមើលថែយ៉ាង ជិតដិតពីសំណាក់គ្រូពេទ្យជាប្រចាំ តាំងពីថ្ងៃដែលខ្លួនចូលក្នុងមណ្ឌលអប់រំកែប្រែទី១ "ម១" មកខ្លួនមានការថប់ដង្ហើម ,វិលមុខ ស្រវាំងភ្នែក រោយក ,ដេកមិនលក់ នោមញឹក អស់កំលាំង ,ជាតិស្ករក្នុងឈាមឡើងខ្ពស់ និងសម្ពាធឈាមឡើងខ្ពស់ ហើយត្រូវលេបថ្នាំជា ប្រចាំនៅក្នុងមណ្ឌល ដោយសារស្ថានភាពជំងឺនេះចាំបាច់ត្រូវការព្យាបាលពីគ្រូពេទ្យជំនាញ។ ម្យ៉ាងវិញទៀតកូនក្តី ខ្លួនមានកូនចំនួន០២នាក់ ដែលជាអនីតិជន នៅក្នុងបន្ទុកដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាអប់រំ ក្រៅពីរូបកូនក្តីខ្លួនឈ្មោះ [redacted] សុផល គឺមិនមានអ្នកណាមើលថែនោះទេ ហើយកូនក្តីខ្លួនក៏ត្រូវបង់ធនាគារ ដែលបានខ្ចីថែមទៀតផង។ ខ្លួនសូម បញ្ជាក់ថា បើតុលាការអនុញ្ញាតឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំនោះ គឺមិនគេចវេះទៅណាឡើយព្រោះអចលវត្ថុ របស់កូនក្តី ខ្លួនត្រូវបានតុលាការចេញដីកាសម្រេចរក្សាការពារលេខ ២៥០ "ញ"ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញរួចរាល់ហើយ ។ ដូច្នេះហើយ ក្នុងនាមខ្លួនជាមេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទចោទ សូមឱ្យតុលាការឱ្យកូនក្តីខ្លួននៅក្រៅឃុំដោយក្តីអនុគ្រោះ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ផា បានសំណូមពរថា៖ ខ្លួនសូមសន្យាថា នៅពេលដែលតុលាការឱ្យខ្លួនបាននៅ ក្រៅឃុំនោះខ្លួននឹងមិនរត់គេចខ្លួនឡើយ ហើយនៅពេលដែលតុលាការកោះហៅពេលណា ខ្លួននិងចូលមកគ្រប់ពេល ដោយមិនគេចវេះនោះទេ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ



Scanned with CamScanner

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការ

## យល់ឃើញថា:

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៦៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ផា** ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧០ ជនជាតិខ្មែរ ជាប់ចោទពីបទ **ឆបោក** និងបទ **ក្លែងបន្លំ** (**ស្នាមមេដៃ**) ប្រព្រឹត្តនៅ រាជធានី-ភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ ,មាត្រា**៣៧៨** និងមាត្រា**៦២៦** ,មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។

២-បានឃើញ ពាក្យសុំដោះលែងកូនក្តីឱ្យនៅក្រៅឃុំ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ផា** ភេទប្រុស ជនជាតិខ្មែរ ជាប់ចោទ ពីបទ **ឆបោក** និងបទ **ក្លែងបន្លំ** (**ស្នាមមេដៃ**) ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧,មាត្រា៣៧៨ និងមាត្រា**៦២៦**,មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។

៣-ជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ផា បានឆ្លើយថា៖ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ មេធាវីការពារសិទ្ធិឱ្យរូបខ្លួនបានដាក់ពាក្យសុំឱ្យនៅក្រៅឃុំដោយមូលហេតុថាខ្លួនមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ហើយត្រូវការមើលថែយ៉ាង ជិតដិតពីសំណាកគ្រូពេទ្យជាប្រចាំ តាំងពីថ្ងៃដែលខ្លួនចូលក្នុងមណ្ឌលអប់រំកែប្រែទី១ "ម១" មកខ្លួនមានការថប់ដង្ហើម ,វិលមុខ ស្រវាំងភ្នែក រោយក ,ដេកមិនលក់ នោមញឹក អស់កំលាំង ,ជាតិស្ករក្នុងឈាមឡើងខ្ពស់ និងសម្ពាធឈាមឡើងខ្ពស់ ហើយត្រូវលេបថ្នាំជាប្រចាំនៅក្នុងមណ្ឌល ដោយសារស្ថានភាពជំងឺនេះចាំបាច់ ត្រូវការព្យាបាលពីគ្រូពេទ្យជំនាញ។ ម្យ៉ាង វិញទៀតខ្លួនមានកូនចំនួន០២នាក់ ដែលជាអនីតិជន នៅក្នុងបន្ទុកដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាអប់រំ ក្រៅពីរូបខ្លួនគឺមិន មានអ្នកណាមើលថែនោះទេ ហើយរូបខ្លួនក៏ត្រូវបង់ធនាគារ ដែលខ្លួនបានខ្ចីថែមទៀតផង។ ខ្លួនសូមសន្យាថា បើតុលាការអនុញ្ញាតឱ្យរូបខ្លួនបាននៅក្រៅឃុំនោះ គឺរូបខ្លួនមិនគេចវេះទៅណាឡើយព្រោះអចលវត្ថុ របស់ខ្លួនត្រូវបានតុលាការចេញ ដីកាសម្រេចរក្សាការពារលេខ ២៥០ "ញ"ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ រួចរាល់ហើយ។

តាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយនាពេលសវនាការ តុលាការពិចារណាឃើញថា គ្មានមូលសមរម្យសម្រាប់ឱ្យជនជាប់ចោទនៅក្រៅឃុំនោះឡើយ ហើយបើតុលាការឱ្យជនជាប់ចោទនៅក្រៅឃុំនោះ ធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ការដែលឱ្យជនជាប់ចោទនៅក្រៅឃុំនោះ អាចធ្វើឱ្យជនជាប់ចោទធ្វើការញុះញង់ឱ្យសាក្សី ឬបំផ្លាញភស្តុតាងដែលបានប្រព្រឹត្តដោយជនជាប់ចោទ បានបន្លំឯកសារ លក់ដី របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀតបើឱ្យជនជាប់ចោទនៅក្រៅឃុំ រួចជនជាប់ចោទរត់គេចខ្លួន ព្យសនកម្ម ដែលកើតឡើងនោះ និងធ្វើឱ្យខូចខាតប្រយោជនរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងធ្ងន់ធ្ងរ ហេតុនេះគប្បីតុលាការ បន្តការឃុំខ្លួនលើជនជាប់ចោទ ដើម្បីទុកចាត់ការតាមនីតិវិធី។



Scanned with CamScanner

៤-លោក [redacted] ជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវលីង ភេទស្រី បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ, ឃើញថា ជនជាប់ចោទគ្មានចេតនាដោះស្រាយចរចាជាមួយកូនក្តីរបស់ខ្លួននៅលើបញ្ហាដែលធ្លាប់បានប្រព្រឹត្តកន្លងមក ។ ហើយជនជាប់ចោទបានបញ្ជាក់ថាខ្លួនមានជំងឺជាប្រចាំ និងមានកូនតូច ដែលនៅក្នុងបន្ទុក កំពុងមានជំងឺថែមទៀតផង ការលើកឡើងពីបញ្ហាជំងឺនេះ គឺគ្រាន់តែជាលេសមួយដើម្បីឱ្យខ្លួនបាននៅក្រៅឃុំតែប៉ុណ្ណោះ ប្រសិនបើតុលាការអនុញ្ញាឱ្យជនជាប់ចោទនៅក្រៅឃុំនោះ ជនជាប់ចោទនិងប្រព្រឹត្តបទល្មើសថ្មីបន្ថែមទៀត ដែលបណ្តាលឱ្យមានភាពវឹកវរដល់សង្គម។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យតុលាការមេត្តារក្សាជនជាប់ចោទឱ្យនៅក្នុងពន្ធនាគារបន្តទៀតដោយក្តីអនុគ្រោះ។ ចំណុច ស្នើសុំរបស់លោកមេធាវីនេះ គប្បីតុលាការនិងលើកយកមកធ្វើការពិចារណា។

៥-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំឱ្យតុលាការធ្វើការឃុំខ្លួនជនជាប់ចោទជាបន្តទៅទៀត ការប្តឹងសុំរបស់ជនជាប់ចោទនេះគឺពុំមានមូលហេតុគ្រប់គ្រាន់ ហើយប្រសិនបើឱ្យជនជាប់ចោទនៅក្រៅឃុំនោះ និងអាចមានភាពច្របូកច្របល់ដែលបង្ករឡើងដោយជនជាប់ចោទ ម្យ៉ាងវិញទៀតជនជាប់ចោទមិនទាន់បានសងសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមិនមានការភ្ញាក់រលឹកពីទង្វើដែលខ្លួនបានប្រព្រឹត្តនោះឡើយ ។ ហេតុដូចនេះ តំណាងអយ្យការ ស្នើសុំដល់ឱ្យរក្សាការឃុំខ្លួនជនជាប់ចោទបន្តដើម្បីទុកជូនតុលាការចាត់ការតាមនីតិវិធី ។ ចំណុចនៃការប្តឹងសុំរបស់តំណាងអយ្យការនេះ គប្បីតុលាការនិងលើកយកមកធ្វើការពិចារណា និងសម្រេចតាមការប្តឹងសុំ នេះ។

៦-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ធា បានធ្វើសេចក្តីសន្និដ្ឋានថា៖ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ មេធាវីការពារ ខ្លួនបានដាក់ពាក្យសុំឱ្យនៅកូនក្តីនៅក្រៅឃុំដោយសារតែកូនក្តីរបស់ខ្លួនមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ហើយត្រូវការមើលថែយ៉ាង ជិតដិតពីសំណាក់គ្រូពេទ្យជាប្រចាំ តាំងពីថ្ងៃដែលខ្លួនចូលក្នុងមណ្ឌលអប់រំកែប្រែទី១ "ម១" មកខ្លួនមានការថប់ដង្ហើម ,វិលមុខ ស្រវាំងភ្នែក រោយក ,ដេកមិនលក់ នោមញឹក អស់កំលាំង ,ជាតិស្ករក្នុងឈាមឡើងខ្ពស់ និងសម្ពាធឈាមឡើងខ្ពស់ ហើយត្រូវលេបថ្នាំ ជាប្រចាំនៅក្នុងមណ្ឌល ដោយសារស្ថានភាពជំងឺនេះចាំបាច់ត្រូវការព្យាបាលពីគ្រូពេទ្យជំនាញ។ ម្យ៉ាងវិញទៀតកូនក្តី ខ្លួនមានកូនចំនួន០២នាក់ ដែលជាអនីតិជន នៅក្នុងបន្ទុកដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាអប់រំ ក្រៅពីរូបកូនក្តីខ្លួនឈ្មោះ [redacted] សុផល គឺមិនមានអ្នកណាមើលថែនោះទេ ហើយកូនក្តីខ្លួនក៏ត្រូវបង់ធនាគារ ដែលបានខ្ចីថែម ទៀតផង។ ខ្លួនសូម បញ្ជាក់ថា បើតុលាការអនុញ្ញាតឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំនោះ គឺមិនគេចវេះទៅណាឡើយព្រោះអចលវត្ថុរបស់កូនក្តី ខ្លួនត្រូវបានតុលាការចេញដីកាសម្រេចរក្សាការពារលេខ ២៥០ "ញ"ដ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញរួចរាល់ហើយ ។ ដូច្នេះហើយ ក្នុងនាមខ្លួនជាមេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទចោទ សូមឱ្យតុលាការឱ្យកូនក្តីខ្លួននៅក្រៅឃុំដោយក្តីអនុគ្រោះ។ ដូច្នេះហើយក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទចោទ សូមឱ្យតុលាការឱ្យកូនក្តីខ្លួននៅក្រៅឃុំដោយក្តីអនុគ្រោះ។ ចំពោះចំណុចស្នើសុំរបស់លោកមេធាវីនេះ គប្បីតុលាការនិង លើកយកមកធ្វើការពិចារណា។

៧- ជនជាប់ចោទឈ្មោះ [redacted] សុផល បានសំណូមពរថា៖ខ្លួនសូមសន្យាថា នៅពេលដែលតុលាការឱ្យខ្លួនបាននៅក្រៅឃុំនោះខ្លួននឹងមិនរត់គេចខ្លួនឡើយ ហើយនៅពេលដែលតុលាការកោះហៅពេលណា ខ្លួននិងចូលមកគ្រប់



Scanned with CamScanner

ពេលដោយមិនគេចវេះនោះទេ។ តុលាការនិងពិចារណាចំពោះការស្នើសុំនេះ និងសម្រេចនៅក្នុងសេចក្តីសម្រេច។

៨-ការនៅក្រៅឃុំរបស់ជនជាប់ចោទគឺ ធ្វើឱ្យប៉ះពាល់ដល់នីតិវិធីរបស់តុលាការ ដោយសារតែជនជាប់ចោទពុំទាន់បានផ្តល់ចម្លើយនៅក្នុងអង្គសវនាការអង្គសេចក្តីនៅឡើយ ហេតុដូច្នេះ គប្បីតុលាការរក្សាជនជាប់ចោទ ដើម្បីទុកជូនតុលាការចាត់ការតាមនីតិវិធី។

## ហេតុដូច្នេះសម្រេច

-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **សុផល** ហៅ **ឆា** ភេទប្រុស កើតថ្ងៃទី០៨ ខែ សីហា ឆ្នាំ១៩៧០ ជនជាតិខ្មែរ ជាប់ចោទពីបទ **ឆបោក** និងបទ **ក្លែងបន្លំ** (**ស្នាមមេដៃ**) ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុង ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧**, មាត្រា**៣៧៨** និង មាត្រា**៦២៦**, មាត្រា**៦២៧** នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុផល ហៅ ផា ,ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ,ចំពោះមុខមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]